# ញត្តិ

## ជូន លោក **អេម៉ានុអែល ម៉ាក្រុង** ( EMMANUEL MACRON )

## ប្រធានាធិបតី នៃ សាធារណរដ្ឋ បារាំង

## និងជា សហប្រធាន នៃកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស ឆ្នាំ១៩៩១ ស្តីពីកម្ពុជា

Palais de l’Elysée,
55, rue du Faubourg Saint-Honoré, 75008  PARIS, France

---

**លោក ប្រធានាធិបតីជាទីគោរព**

យើងខ្ញុំ ជាតំណាងសហគមន៍ខ្មែរ ព្រមទាំងញាតិមិត្ត រស់នៅក្នុងប្រទេសបារាំង និង ក្នុងទ្វិបអឺរ៉ុប បានរួមប្រជុំគ្នាជាមហាបាតុកម្ម នៅទីលានសិទ្ធិមនុស្ស នៃទីក្រុងប៉ារីស នាថ្ងៃទី៩ សីហា ២០១៧ នេះ ដើម្បីសំដែង នូវសេចក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅ និងកំហឹងជាខ្លាំង

ចំពោះ អំពើផ្តាច់ការ របស់លោកហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា និងបក្សរបស់គាត់ ដោយការរំលោភដោយចេតនា លើកិច្ចព្រមព្រៀងសន្តិភាព នៅទីក្រុងប៉ារីស ថ្ងៃទី២៣ តុលា ១៩៩១ ហើយជំរុញ អនាគតនៃប្រទេស និងប្រជាជនខ្មែរ អោយប្រឈមមុខ និងគ្រោះថ្នាក់ យ៉ាងធ្ងន់ធ្ងរណាស់។

**ដោយបុព្វហេតុថា :**

- ចាប់តាំងពីរដ្ឋប្រហារបង្ហូរឈាម របស់គាត់ ពីថ្ងៃទី៥-៦កក្កដា១៩៩៧ ទម្លាក់សហនាយករដ្ឋមន្ត្រី នរោត្តម រណឫទ្ធិ មក លោកហ៊ុន សែន បានធ្វើច្បាប់និងបទប្បញ្ញត្តិ ជាបន្តបន្ទាប់ ដើម្បីរឹតត្បឹត សិទ្ធិ និងសេរីភាពសាធារណៈ នៃបក្សជំទាស់ទាំងអស់ នៃសហជិពឯករាជ និងអ្នកមិនសប្បាយចិត្តនិងអាជ្ញាធររដ្ឋ ព្រមទាំងកៀបសង្កត់ បំបិតសម្លេងរិះគន់ទាំងអស់ ដើម្បីបង្កើតអំណាចផ្តាច់ការរបស់គាត់ និងភាព"ស្របច្បាប់" នៃការបង្ក្រាបជិះជាន់របស់គាត់នោះ។

- ជាបន្ទាប់ ចាប់តាំងពីឆ្នាំ២០១៤ បន្ទាប់ពីបរាជ័យដ៏ជូរចត់ របស់ខ្លួន នៅក្នុងការបោះឆ្នោត នៃខែកក្កដាឆ្នាំ ២០១៣ លោកហ៊ុន សែន បានហាមមិនអោយមាន ការធ្វើបាតុកម្មជាសាធារណៈទាំងអស់ នៃបក្សជំទាស់ នៃសហជីពឯករាជ និងក្រុមអ្នកតវ៉ាការពារសិទ្ធិនិងទ្រព្យសម្បត្តិរបស់ពួកគេ។ គាត់បានបញ្ជា អោយកងយោធារបស់គាត់ បាញ់ទៅលើក្រុមកម្មករជាបាតុករ និងចាប់អ្នកតវ៉ា និងសមាជិក

សំខាន់ៗ នៃបក្សជំទាស់ ទៅញាត់ក្នុងគុក ដោយចោទប្រកាន់ថា ពួកគេបាន "បង្កចលាចលផ្ទៃក្នុង ឬ បាននាំគ្នាបះបោរ ឬ មានបំណងធ្វើអបគមន៍នៃប្រទេស។ល។"

- នៅឆ្នាំ២០១៦ និងឆ្នាំ២០១៧នេះ ក្នុងការបំរុងធ្វើការបោះឆ្នោត នាខែកក្កដាឆ្នាំ២០១៨ ខាងមុខ លោកហ៊ុន សែន បក្ស និងពួកទ័ព របស់គាត់ បានស្រែក គំរាមកំហែងជាសាធារណៈ ថានឹងមានផ្ទុះសង្គ្រាមស៊ីវិល ឬ រដ្ឋប្រហារមួយ នៃពួកឧត្តមសេនីយ៍យោធានិងប៉ូលីស មិនខានឡើយ ប្រសិនបើបក្សរបស់ពួកគេត្រូវចាញ់ ក្នុងការបោះឆ្នោតនោះ។

- ហើយ នាពេលចុងក្រោយនេះ ដើម្បីបង្ហាញ នូវការចាំបាច់ដាច់ខាត អោយគាត់កាន់អំណាច តទៅទៀត លោកហ៊ុន សែន បានបង្កើតព្រឹត្តិការណ៍ ក្លែងក្លាយថា មានការ គំរាមកំហែងកាន់តែខ្លាំងឡើងទៀត ដែលមកពី "អំណាចបរទេស" គឺ "សហរដ្ឋអាមេរិក" ដែលគាត់ថា បានរៀបចំការផ្តួលរំលំគាត់ និងបំផ្លាញស្ថិរភាព នៃប្រទេសកម្ពុជា ដោយមាន"ការឃុបឃឹត របស់ កឹម សុខា"។ ការចោទប្រកាន់នេះ គ្មានមូលដ្ឋាន ច្បាស់លាស់សោះឡើយ។ លោក កឹម សុខា ដែលជាសមាជិករដ្ឋសភា និងជាប្រធានគណបក្សជំទាស់ ដ៏សំខាន់ ត្រូវបានចាប់ខ្លួន នៅផ្ទះរបស់លោក នៅពេលកណ្តាលអធ្រាត្រ នៃថ្ងៃទី២ឆ្លៀងទៅថ្ងៃទី៣ កញ្ញា ដោយការវាយឆ្មក់ នៃកងប៉ូលិស ចំនួនប្រមាណ១០០-២០០នាក់។ ការប្រព្រឹត្ត របៀបនេះ គឺខុសច្បាប់ពេញទី ៖ ១ គឺ គ្មានដីកាត្រឹមត្រូវតាមច្បាប់, ២ គឺ រំលោភលើអភ័យឯកសិទ្ធិ លោក កឹម សុខា ដែលជាតំណាងរាស្ត្រ, ៣ គឺ ការមកចាប់ខ្លួនលោក សុខា ក្នុង ពេលកណ្តាលអធ្រាត្រ ដោយគ្មានបទល្មើសដោយជាក់ស្តែង។ ក្នុងពេលនេះដែរ អ្នកកាសែត និង ប្រព័ន្ធផ្សព្វផ្សាយឯករាជ ត្រូវបានពួកអំណាចហ៊ុន សែន វាយប្រហារ ហើយបិទការផ្សាយ បិទ សម្លេង អោយស្ងាត់ច្រៀប ទាំងអស់។

## លោកប្រធានាធិបតី

អស់រយៈពេល២០ឆ្នាំមកហើយ រហូតមកដល់បច្ចុប្បន្ននេះទៀត អង្គការមនុស្សធម៌អន្តរជាតិធំៗ តំណាងនានានៃអង្គការសហប្រជាជាតិ សមាជិកសភានៅអឺរ៉ុប និងនៅអាស៊ីអាគ្នេយ៍ បានធ្វើបន្ទាល់ និងបានបរិហារ ជាច្រើនដងណាស់មកហើយ អំពីអំណាចផ្តាច់ការ មហាពុករលួយ និងការគៀបសង្កត់ឃោរឃៅ របស់ ហ៊ុន សែន (អតីតមេបញ្ជាការម្នាក់ របស់ខ្មែរក្រហម) និងបក្សពួករបស់គាត់ ដែលបានរំលោភដោយចេតណា ឥតឈប់ឈរ លើសិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះ រំលោភលើរដ្ឋធម្មនុញ្ញ របស់ប្រទេស និងរំលោភលើគោលការណ៍ប្រជាធិបតេយ្យពហុបក្ស នៅកម្ពុជា។ ប្រជាជនខ្មែរត្រូវបាន រស់នៅម្តងទៀត ក្រោមការគំរាមកំហែងនៃការកាប់សម្លាប់ និងសង្គ្រាមផ្ទៃក្នុង ឬមកពីខាងក្រៅ ដែលធ្វើនិងបង្ករ ដោយ"មេដឹកនាំ"របស់ខ្លួនឯងតែម្តង។

**ដោយសារហេតុផលទាំងនេះ**

យើងខ្ញុំ សូមអំពាវនាវយ៉ាងទទូចបំផុត ដល់លោកប្រធានាធិបតី ដែលមានសមត្ថភាពកិត្តិយស ជាសហប្រធាន នៃកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស ស្តីពីកម្ពុជា ឆ្នាំ១៩៩១ សូមអោយពិចារណា នូវការបង្កើតជាបន្ទាន់ នូវគណៈកម្មការអន្តរជាតិមួយ ត្រួតពិនិត្យ ការអនុវត្តន៍ជាក់ស្តែង នៃកិច្ចព្រមព្រៀងហ្នឹង ដើម្បីបង្ខំឱ្យនាយករដ្ឋមន្ត្រី ហ៊ុន សែន និង បក្សរបស់គាត់ ឈប់ប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ប្រឆាំងនឹងប្រជាជនខ្មែរ, អោយដោះលែងលោក កឹម សុខា និងអ្នកជាប់គុក-ជាប់ទោសនយោបាយទាំងអស់ ជាបន្ទាន់ ដោយគ្មានលក្ខខណ្ឌ និងផ្តល់កិត្តិយសជាថ្មី អោយពួកគេវិញ ព្រមទាំងបើកឡើងវិញ នូវសេរីភាព នៃការបញ្ចេញមតិយោបល់ និងសេរីភាពសារពត៌មាន គឺថាអោយលោកហ៊ុន សែន និងបក្សរបស់គាត់ បែរ ទៅកាន់សេចក្តីសន្យា របស់គាត់ នៅក្នុងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីស ដែលថាគាត់គោរពយ៉ាងម៉ត់ចត់បំផុត ចំពោះបទប្បញ្ញត្តិទាំងអស់ និងស្មារតី នៃកិច្ចព្រមព្រៀងហ្នឹង។

សូមលោកប្រធានាធិបតី ទទួលនូវ អំណរគុណ និង សេចក្តីគោរពដ៏ខ្ពង់ខ្ពស់ អំពីយើងខ្ញុំ។

ធ្វើនៅទីក្រុងប៉ារីស (ប្រទេសបារាំង) ថ្ងៃទី៩ខែកញ្ញាឆ្នាំ២០១៧

*អ្នកតំណាង បាតុករ*ទាំងអស់

**លោក យុនសារុន**



M. François-Paul YUN

M. François-Paul YUN
Association Solidarité Khmère
4, rue de la Chapelle
75018 Paris
Tél : +33 6 81 46 29 08
e_mail : francois.yfp@gmail.com